# សេចក្តីថ្លែងការណ៍

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីព្រះសង្ឃខ្មែរកម្ពុជាក្រោមពីរព្រះអង្គត្រូវអាជ្ញាធរខ្មែរចាប់ផ្សឹករួចបញ្ជូនទៅប្រទេសវៀតណាមវិញ

Website: www.hoksavann.org

ថ្ងៃទី២០ វិច្ឆិកា ២០០៤

កាលពីថ្ងៃ១១វិច្ឆិកា ព្រះសង្ឃខ្មែរកម្ពុជាក្រោមពីរអង្គគង់នៅវត្តធ្លង់ ឃុំធ្លង់ ស្រុករំដួល ខេត្តស្វាយរៀង បានត្រូវប៉ូលិសអន្តោប្រវេសន៏ខ្មែរខេត្តស្វាយរៀងចាប់ផ្សឹក រួចបញ្ជូនទៅប្រទេសវៀតណាមវិញ ។

អាត្មាមានការសោកស្តាយលាយដោយការរន្ធត់ណាស់ ខ្មែរយើងអ្នកគោរពព្រះពុទ្ធសាសនា មិនគួរធ្វើដល់ថ្នាក់នេះទេ ។ អំពើដែលអាជ្ញាធរខ្មែរធ្វើមកលើព្រះសង្ឃខ្មែរកម្ពុជាក្រោមនេះមានកំហុសពីរជាន់ ៖

១- គ្រហត្ថត្រូវផ្សឹកព្រះសង្ឃ ដែលបួសត្រឹមត្រូវតាមវិន័យបញ្ញត្តិរបស់ព្រះពុទ្ធ ។ បើទោះបីព្រះសង្ឃមានកំហុសដល់ថ្នាក់ឧក្រិដ្ឋ ដូចជាសម្លាប់មនុស្សជាដើម ត្រូវប្រគល់ឲ្យគណៈសង្ឃជំរះទៅតាមព្រះវិន័យជាមុន ព្រោះខ្មែរយើងមានគណៈសង្ឃខាងពុទ្ធចក្រ មិនត្រូវរំលងធ្វើបំពានដូចទមិឡតតសាសនានោះទេ គ្រហស្ថទៅផ្សឹកព្រះសង្ឃបែបនេះមានទោសធ្ងន់ណាស់ក្នុងពុទ្ធសាសនា ។

២- ការបញ្ជូនទៅវិញដោយបង្ខំនេះ ចាត់ទុកជាការរំលោភច្បាប់អន្តរជាតិ ដែលខ្មែរក៏បានចុះហត្ថលេខាទទួលស្គាល់ ស្តីអំពីជនភៀសខ្លួនដែលរត់មកជ្រកកោនប្រទេសណាមួយ ដែលប្រទេសខ្លួនត្រូវធ្វើទុក្ខបុកម្នេញ ការបញ្ជូនទៅវិញនោះ ពុំដឹងជាវៀតណាមធ្វើបាបយ៉ាងណាទេ ។ បើលិខិតឆ្លងដែនត្រឹមត្រូវៗតែឲ្យចូលតាមច្បាប់ ។ បើទោះបីគ្មានលិខិតឆ្លងដែនក៏ដោយ ក៏ព្រះអតីតព្រះមហាក្សត្រខ្មែរនិងរាជរដ្ឋាភិបាលគ្រប់ជំនាន់ តែងចាត់ទុកខ្មែរកម្ពុជាក្រោមជាខ្មែរពេញលក្ខណៈ រាជរដ្ឋាភិបាលខ្មែរតែងទទួលស្វាគមន៍ ។ ការបញ្ជូនទៅវិញនេះ ចាត់ទុកថាអាជ្ញាធរខ្មែរបំរើផលប្រយោជន៍ប្រទេសវៀតណាមយ៉ាងពិតប្រាកដណាស់ ព្រោះព្រះសង្ឃខ្លះចូលមកខ្មែរកណ្តាល ដើម្បីសិក្សារៀនសូត្រព្រះពុទ្ធសាសនា ហើយយកទៅផ្សាយនៅខ្មែរកម្ពុជាក្រោមវិញ ហើយវៀតណាមមិនចង់ឲ្យខ្មែរចេះដឹងអ្វីទេ ។ ហេតុអ្វីក៏ខ្មែរកណ្តាលទុកខ្មែរកម្ពុជាក្រោមជាខ្មាំង ដែលជាសាច់ឈាមរបស់ខ្លួនពីដើម មិនទទួលយកព្រះសង្ឃពីកម្ពុជាក្រោមឲ្យលោកសិក្សាផង ។ ឬមួយប៉ូលិសអន្តោប្រវេសន៍នោះជាភ្នាក់ងារវៀតណាមបង្កប់ខ្លួន ។ ផ្ទុយទៅវិញ បើជនជាតិវៀតណាមចូលមកដីខ្មែរវិញ អាជ្ញាធរខ្មែរបើកឲ្យចូលយ៉ាងស្រួល ។

ទីបំផុត សូមអំពាវនាវក្រសួងមានសមត្ថកិច្ចនៃអាជ្ញាធរខ្មែរ ជាពិសេសក្រសួងមហាផ្ទៃ សូមបើកការស៊ើបអង្កេតជាបន្ទាន់បំផុត ចំពោះករណីប៉ូលិសអន្តោប្រវេសន៍ខេត្តស្វាយរៀង ដែលបានប្រព្រឹត្តអំពើអមនុស្សធម៌ខុសច្បាប់ទម្លាប់នេះ ហើយបញ្ជូនទៅតុលាការកាត់ទោសតាមច្បាប់ ដើម្បីទុកជាគំរូកុំឲ្យកន្លែងដទៃទៀតប្រព្រឹត្តអំពើបែបនេះតទៅទៀត ។ ផ្ទុយទៅវិញ បើទំរើនេះកើតពីក្រសួងមហាផ្ទៃបញ្ជាឲ្យធ្វើទេ នោះបញ្ហានេះធ្លាក់ទៅលើរាជរដ្ឋាភិបាលទទួលខុសត្រូវ គឺជាផែនការរបស់រាជរដ្ឋាភិបាល ដែលកំចាត់ខ្មែរកម្ពុជាក្រោមដើម្បីផ្គាប់ចិត្តវៀតណាម ។

វត្តខ្មែរកាណាដា, ថ្ងៃ១៩ វិច្ឆិកា ២០០៤

ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ